ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ៩៤៨/២៤ ក.ប/ខ.ល

**សារលិខិតអបអរសាទរ**

**សូមគោរពជូន**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

ក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយទឹកចិត្តសោមនស្សរីករាយ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា សូមសម្តែងនូវអំណរសាទរយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសទទួលបានពានរង្វាន់ «**ភាពជាអ្នកដឹកនាំឆ្នើមពិភពលោក**» ពីវិទ្យាស្ថានយុទ្ធសាស្ត្រសម្រាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិក (KSI) នាព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤។

«**ភាពជាអ្នកដឹកនាំឆ្នើមពិភពលោក**» ដែលត្រូវបានប្រគល់ជូន **សម្តេចមហាបវរធិបតី** នាពេលនេះគឺពិតជាស័ក្តិសមបំផុតចំពោះ **សម្តេចធិបតី** ដែលបាននិងកំពុងដឹកនាំនាវាកម្ពុជា ប្រកបដោយភាពស្វាហាប់ យកអស់កម្លាំងកាយ បញ្ញាស្មារតី ដើម្បីបន្តថែរក្សាសន្តិភាព ការពារនូវអធិបតេយ្យភាព ឯករាជ្យជាតិ បូរណភាពទឹកដី ដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍជាតិ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងទទួលខុសត្រូវខ្ពស់របស់ **សម្តេចធិបតី** រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ធ្វើឱ្យកម្ពុជាមានការអភិវឌ្ឍលើគ្រប់វិស័យ មានប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាបន្ន សេដ្ឋកិច្ចរីកចម្រើនប្រកបដោយចីរភាព និងសមធម៌ កិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយបណ្តាប្រទេសលើសកលលោក និងចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់ និងពិភពលោក។

ឆ្លៀតក្នុងឱកាសដ៏មហាមង្គលាភិរម្យថ្ងៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តិសិទ្ធក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ ជូនចំពោះ **សម្តេចមហាបវរធិបតី** និង**លោកជំទាវបណ្ឌិត** ព្រមទាំងបុត្រា បុត្រី សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវកិច្ចភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ អង្គារ ១០រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**